# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦

## ជប៉ុនផ្តល់ ១៣៤,៥២៦ ដុល្លារអាមេរិក សម្រាប់គម្រោងពង្រឹងប្រព័ន្ធថែទាំសុខភាពបឋមមាតា និងទារកនៅខេត្តកំពង់ចាម

ក្រោមគ្រោងការណ៍នៃជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុន បានផ្តល់១៣៤,៥២៦ដុល្លារអាមេរិក ដល់អង្គការមូលនិធិជប៉ុនPHJ។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោកស្រី ណាកាតា យូស៊ីមិ នាយិកាប្រចាំប្រទេសអង្គការមូលនិធិជប៉ុនPHJ នៅស្ថានទូតជប៉ុន ដើម្បីអនុវត្ត "គម្រោងពង្រឹងប្រព័ន្ធថែទាំសុខភាពបឋមមាតា និងទារកនៅខេត្តកំពង់ចាម" ។

ក្នុងគម្រោងនេះ អង្គការមូលនិធិជប៉ុនPHJ នឹងពង្រឹងប្រព័ន្ធសុខភាពនៅស្រុកប្រតិបត្តិស្ទឹងត្រង់ ខេត្តកំពង់ចាម តាមរយៈការជួយដល់ការគ្រប់គ្រងស្រុកប្រតិបត្តិស្ទឹងត្រង់នេះ និងការផ្តល់វគ្គបណ្តុះបណ្តាលជាច្រើនដល់ឆ្មបកម្រិតមធ្យមតាមមណ្ឌលសុខភាពគោលដៅ ព្រមទាំងអ្នកស្ម័គ្រចិត្តសុខាភិបាលតាមភូមិមួយចំនួនដែលស្ថិតនៅក្នុងស្រុកប្រតិបត្តិនេះផងដែរ។ អង្គការមូលនិធិជប៉ុនPHJ ក៏នឹងគាំទ្រដល់ការជួសជុល និងការកែលម្អមណ្ឌលសុខភាព ព្រមទាំងបំពាក់នូវបរិក្ខាពេទ្យមួយចំនួននៅក្នុងមណ្ឌលសុខភាពគោលដៅទាំងអស់នោះផងដែរ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ត្រូវបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២ រដ្ឋាភិបាលជប៉ុន បានផ្តល់ប្រមាណជា ២៦.១ លានដុល្លារអាមេរិក ដល់គម្រោងចំនួន៩៤ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល កសិកម្ម និងសកម្មភាពបោសសំអាតមីន។ គម្រោងដែលត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ គឺជាគម្រោងទី២ តាមរយៈគ្រោងការណ៍នៃជំនួយនេះនៅកម្ពុជា សម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៦របស់ជប៉ុន (មេសា ២០១៦ ដល់មិនា ២០១៧)៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣១០*
*អ៊ីមែល:* eco.jpn@pp.mofa.go.jp
*គេហទំព័រផ្លូវការ:* www.kh.emb-japan.go.jp